# កិច្ចព្រមព្រៀងបំពេញបន្ថែម
# រវាងអង្គការសហប្រជាជាតិ
# និង រាជរដ្ឋាភិបាលកម្ពុជា
# បន្ថែមទៅលើ
# កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ
# ទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា
# នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្ដីពីសម្ភារៈប្រើប្រាស់ ការជួយសម្រួល និងសេវាកម្ម

*ដោយហេតុថា* នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (តទៅនេះហៅថា "**កិច្ចព្រមព្រៀង**")

*ដោយហេតុថា* មាត្រា ១៤ នៃកិច្ចព្រមព្រៀងចែងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្ដល់និងត្រូវរ៉ាប់រងចំណាយដោយខ្លួនឯង នូវអាគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ដែលមានចែងនៅក្នុង**កិច្ចព្រមព្រៀង**

*ដោយហេតុថា* មាត្រា ១៤ នៃ**កិច្ចព្រមព្រៀង**ចែងបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្ដល់នូវសម្ភារៈប្រើប្រាស់ ការជួយសម្រួល និងសេវាកម្មផ្សេងៗទៀតដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់អង្គជំនុំជម្រះ ដែលអាចឯកភាពគ្នាបានតាមរយៈកិច្ចព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា

*ដោយហេតុថា* មាត្រា ១៧(ខ) នៃ**កិច្ចព្រមព្រៀង**ចែងថា អង្គការសហប្រជាតិត្រូវទទួលខុសត្រូវលើការចំណាយថ្លៃទឹក ភ្លើង ទូរស័ព្ទ ។ល។ ឬសេវាផ្សេងៗ ដោយមានការព្រមព្រៀងគ្នាដោយឡែក រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា

*ដោយហេតុថា* រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថា អនុលោមតាមការទទួលខុសត្រូវរបស់ខ្លួនយោងតាមមាត្រា ១៤ នៃ**កិច្ចព្រមព្រៀង** រាជរដ្ឋាភិបាលនឹងផ្ដល់ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង សម្រាប់រយៈពេលនៃកិច្ចព្រមព្រៀង នូវផ្នែកខ្លះនៃ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ នៅភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្ដាល ដែលបានបញ្ជាក់នៅលើប្លង់ទីតាំងដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងបំពេញបន្ថែម ធ្វើជាអាគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល (តទៅនេះហៅថា "អាគារ")

*ក្នុងគោលបំណង*សម្រេចបាននូវកិច្ចព្រមព្រៀងបំពេញបន្ថែម ដែលត្រូវបានប្រមើលទុកនៅក្នុងមាត្រា ១៤ និង មាត្រា ១៧(ខ) នៃកិច្ចព្រមព្រៀង

*អាស្រ័យហេតុនេះ* អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងដូចខាងក្រោម៖

## មាត្រា ១
## ការកែលម្អ ការកែសម្រួល និងការតុបតែងអាគារ

១. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធ្វើការកែលម្អ និងការកែសម្រួលទៅលើអាគារតាមការចាំបាច់ និងសមស្រប ដើម្បីឱ្យអាគារទាំងនោះរួចរាល់សម្រាប់ការប្រើប្រាស់ដោយ

សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ ការកែលម្អ និងការកែសម្រួលបែបទាំងនោះត្រូវរួមបញ្ចូល តែមិនកម្រិតត្រឹមតែការដំឡើងជញ្ជាំងបាំងខាងក្នុង និងការបំពាក់ហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនងសម្រាប់កុំព្យូទ័រ ទូរសព្ទ ទូរលេខ ទូរសារ និងអ៊ីម៉ែល ស្របតាមលក្ខខណ្ឌបច្ចេកទេសបែបនោះ ដែលអាចឯកភាពគ្នាបានតាមរយៈកិច្ចព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាអាចស្នើសុំជំនួយហិរញ្ញវត្ថុពីរដ្ឋម្ចាស់ជំនួយ ឬអង្គការ ដោយមានគោលបំណងធ្វើឱ្យខ្លួនអាចបង្វែរបន្ទុកថ្លៃចំណាយលើការកែលម្អ និងការកែសម្រួលផ្សេងៗ។

២. អង្គការសហប្រជាជាតិ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវមានសិទ្ធិ ដាក់បង្គោលទង់ជាតិ និងស្លាកការិយាល័យ និងគ្រឿងសម្គាល់នៅខាងក្រៅ និងខាងក្នុងអាគារ។ ទំហំ និងទីតាំងនៃបង្គោលទង់ជាតិ និងស្លាកសញ្ញា និងគ្រឿងសម្គាល់ត្រូវឯកភាពគ្នាដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ បង្គោលទង់ជាតិ និងស្លាកសញ្ញា និងគ្រឿងសម្គាល់ទាំងនោះ ត្រូវជា និងនៅតែជាកម្មសិទ្ធិរបស់អង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវមានសិទ្ធិដកចេញនៅពេលណាក៏បាន នូវបង្គោលទង់ជាតិ និងស្លាកការិយាល័យ និងគ្រឿងសម្គាល់ការិយាល័យណាមួយ ឬទាំងស្រុង ដែលខ្លួនអាចដាក់នៅក្រៅ និងនៅលើអាគារ ហើយការរុះរើនេះត្រូវធ្វើមុនការបញ្ចប់កិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

៣. អង្គការសហប្រជាជាតិ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវមានសិទ្ធិបំពាក់នៅលើអាគារនូវប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធប្រាស្រ័យទំនាក់ទំនងអេឡិចត្រូនិក និងឧបករណ៍សន្តិសុខ។ ប្រព័ន្ធ និងឧបករណ៍ទាំងអស់នោះត្រូវតែជា និងនៅតែជាទ្រព្យសម្បត្តិរបស់អង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង នៅពេលណាក៏ដោយ ត្រូវមានសិទ្ធិរុះរើប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធប្រាស្រ័យទំនាក់ទំនងអេឡិចត្រូនិក និងឧបករណ៍សន្តិសុខមួយចំនួន ឬទាំងស្រុង ដែលខ្លួនអាចបំពាក់នៅលើអាគារ។

៤. ពេលបញ្ចប់ការកាន់កាប់អាគារ ដោយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល អង្គការសហប្រជាជាតិ មិនត្រូវមានកាតព្វកិច្ចណាមួយ ក្នុងការធ្វើឱ្យអាគារមានលក្ខណៈដូចដើមវិញ ដូចទៅនឹងពេលដែលការកាន់កាប់បែបនេះបានចាប់ផ្តើមនោះទេ។

## មាត្រា ២
## ការថែទាំ និងការជួសជុលអាគារ

១. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវថែទាំអាគារ ជាអាទិ៍ រួមមានឧបករណ៍ម៉ាស៊ីនត្រជាក់ បង្គន់អនាម័យ និងទីធ្លា ក្នុងការជួសជុលឱ្យបានល្អពេញមួយអំឡុងពេលនៃ**កិច្ចព្រមព្រៀង**។ រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ក៏ត្រូវទទួលខុសត្រូវចំពោះ ការជួសជុលបន្តិចបន្តួច និងការថែទាំជាប្រចាំ របស់អាគារ ជាអាទិ៍ រួមមាន ឧបករណ៍ម៉ាស៊ីនត្រជាក់ បង្គន់អនាម័យ និងទីធ្លា ដែលកើតចេញពីការកាន់កាប់ និងការប្រើប្រាស់របស់ពួកគេ ពេញមួយរយៈពេលនៃ**កិច្ចព្រមព្រៀង**។

២. ការងារទាំងអស់ដែលប្រតិបត្តិអនុលោមតាមកថាខណ្ឌ ១ ខាងលើ ត្រូវអនុវត្ត ប្រសិនបើអាចធ្វើទៅបាន ក្នុងលក្ខណៈមួយដែលមិនបង្កការរំខានដល់ សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ហើយប្រសិនបើមានការរំខាន និងក្នុងលក្ខខណ្ឌដែលមិនអាចជៀសវាងបាន ត្រូវធានាថាការរំខានបែបនោះមានតិចតួចបំផុត។

## មាត្រា ៣
## សម្ភារៈប្រើប្រាស់ និងសេវាកម្ម

១. រាជរដ្ឋាភិបាលកម្ពុជាធ្វើការធានាថា អាគារត្រូវបានផ្គត់ផ្គង់ដោយសម្ភារៈប្រើប្រាស់ និងសេវាកម្មខាងក្រោម ក្នុងលក្ខណៈ និងក្នុងទំហំដែលគ្រប់គ្រាន់ដើម្បីធានាបាននូវការបំពេញការងារដោយរលូនរបស់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល៖

- (ក) អគ្គិសនី
- (ខ) ទឹកប្រើប្រាស់
- (គ) ទឹកផឹក
- (ឃ) សំណល់ និងការបង្ហូរកាកសំណល់
- (ង) ប្រៃសណីយ៍ សម្រាប់ការប្រមូលនៅជិតការិយាល័យប្រៃសណីយ៍ជិតបំផុត
- (ច) ទូរគមនាគមន៍ រួមមាន ទូរសព្ទ ទូរលេខ ទូរសារ និងអ៊ីមែល សម្រាប់ក្នុងតំបន់ ការទំនាក់ទំនងជាតិ និងអន្តរជាតិ តាមមធ្យោបាយបណ្ដាញតាមដី និងតាមទូរសព្ទ
- (ឆ) ការប្រមូល និងការចោលសំរាម
- (ជ) សេវាសំអាត ដែលគ្រប់គ្រាន់ល្មមដើម្បីថែរក្សាផ្នែកទាំងអស់នៃអាគារក្នុងស្ថានភាព និងស្តង់ដារមួយដែលស្អាតសមស្របសម្រាប់ការប្រើប្រាស់ តាមគោលបំណងដែលគេចង់ប្រើប្រាស់ អនុលោមតាម**កិច្ចព្រមព្រៀង**
- (ឈ) សេវាសង្គ្រោះបន្ទាន់ក្នុងករណីមានអគ្គិភ័យ
- (ញ) ការគ្រប់គ្រងសត្វល្អិតចង្រៃ រួមមានការបាញ់ថ្នាំកម្ចាត់មូស ទាំងខាងក្នុងអាគារ និងនៅតាមបរិវេណជាប់ជុំវិញអាគារ និង
- (ដ) សេវាកម្មម្ហូបអាហារ

២. ប្រសិនបើ និងក្នុងលក្ខខណ្ឌដែលអាចចាំបាច់ រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធានាថាការងារចាំបាច់ទាំងអស់ត្រូវបានអនុវត្ត ហើយហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងអស់ត្រូវបានដាក់ និងថែទាំនៅនឹងកន្លែង ដើម្បីធានាថាសម្ភារៈប្រើប្រាស់ និងសេវាកម្មដែលបានបញ្ជាក់ក្នុងកថាខណ្ឌ ១ ត្រូវបាននាំយកមកកាន់ និងអាចរកបាននៅក្នុងអាគារ ក្នុងករណីទូរគមនាគមន៍ រួមបញ្ចូលទាំងការដំឡើងខ្សែភ្លើងចុងក្រោយទាំងអស់ចូលទៅក្នុង និងក្នុងអាគារ និងការដំឡើងអង់តែនបណ្ដាញទូរសព្ទចល័តដែលចាំបាច់ទាំងអស់។

៣. រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើឱ្យប្រាកដថា សម្ភារៈប្រើប្រាស់ និងសេវាកម្មដែលបញ្ជាក់ក្នុងកថាខណ្ឌ ១ (ក), (ខ), (ឃ), (ច) និង (ឈ) ត្រូវបានផ្គត់ផ្គង់ដល់អាគាររៀងរាល់ថ្ងៃ និងគ្រប់ពេល និងម៉ោង ទោះជាក្នុងថ្ងៃធ្វើការ ឬម៉ោងធ្វើការ ឬផ្សេងពីនេះ។ ដើម្បីបំពេញកាតព្វកិច្ចនេះ ទាក់ទងនឹងការផ្គត់ផ្គង់អគ្គិសនី រាជរដ្ឋាភិបាលកម្ពុជាត្រូវ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង បំពាក់នៅក្នុងអាគារនូវម៉ាស៊ីនភ្លើងចំនួនពីរ ឬច្រើន ឬឧបករណ៍ស្រដៀងគ្នានេះ ដើម្បីបម្រើជាប្រភពអគ្គិសនីបម្រុងសម្រាប់សេវាកម្ម និងឧបករណ៍ទាំងអស់ ក្នុងករណីមានការកាត់ផ្ដាច់ ឬការរំខានដល់ការផ្គត់ផ្គង់មេ។

៤. ក្នុងករណីមានការកាត់ផ្ដាច់ ឬការគំរាមអំពីការកាត់ផ្ដាច់ ទោះជាដោយសារកូដកម្ម ការលំបាកផ្នែកមេកានិច ឬមូលហេតុផ្សេងទៀតក៏ដោយ មកលើសម្ភារៈប្រើប្រាស់ និងសេវាកម្មណាមួយដែលមានបញ្ជាក់ក្នុងកថាខណ្ឌ ១ រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់ទុកតម្រូវការចាំបាច់របស់អាគារ មានសារៈសំខាន់ដូចគ្នាទៅនឹងតម្រូវការចាំបាច់របស់ស្ថាប័នសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជាដែរ ហើយត្រូវចាត់វិធានការតាមនីតិវិធី ដើម្បីធានាថាការងាររបស់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាលមិនត្រូវបានប៉ះពាល់។

៥. រាជរដ្ឋាភិបាលកម្ពុជា អនុវត្តការរៀបចំកិច្ចសន្យាតាមការចាំបាច់ជាមួយអ្នកផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ ឬសេវាកម្មក្នុងស្រុក ដែលមានចែងក្នុងកថាខណ្ឌទី ១ ដើម្បីធានាការផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ ឬសេវាកម្មទាំងនោះដល់អាគារ។

## មាត្រា ៤
## ថ្លៃចំណាយលើសម្ភារៈប្រើប្រាស់ និងសេវាកម្ម

១. រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវលើបន្ទុកថ្លៃចំណាយទាំងអស់សម្រាប់ការប្រើប្រាស់ និងដែលកើតចេញពីការប្រើប្រាស់ សម្ភារៈប្រើប្រាស់ និងសេវាកម្មដែលផ្គត់ផ្គង់ អនុលោមតាមមាត្រា ៣ កថាខណ្ឌ ១ (ក), (ខ), (គ), (ឃ), (ង), (ឆ), (ជ), (ឈ), (ញ) និង (ដ) នៃកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

២. ទាក់ទងទៅនឹងសេវាកម្មទូរគមនាគមន៍ ដែលត្រូវបានផ្ដល់អនុលោមតាមមាត្រា ៣ កថាខណ្ឌ ១(ច) នៃកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ៖

(ក) អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវចំពោះថ្លៃចំណាយសមហេតុផល នៃការបង្កើត និងការរក្សាការតភ្ជាប់ជាមួយបណ្ដាញទូរគមនាគមន៍តាមដី និងតាមទូរសព្ទ។

(ខ) អង្គការសហប្រជាជាតិក៏ត្រូវទទួលខុសត្រូវផងដែរ ចំពោះតម្លៃសមហេតុផលសម្រាប់ការប្រើប្រាស់បណ្ដាញទាំងនោះ ដោយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ តម្លៃបែបនេះនឹងត្រូវយកទៅតាមពន្ធដែលមិនត្រូវលើសពីអត្រាទាបបំផុតដែលអាចប្រៀបធៀបបាន ដែលស្របទៅនឹងស្ថាប័ន និងអង្គភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។

(គ) ទាក់ទងនឹងតម្លៃសម្រាប់ការប្រើប្រាស់បណ្ដាញទូរគមនាគមន៍តាមដីក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាត្រូវបញ្ជូនវិក្កយបត្តប្រចាំខែទៅអនុប្រធានការិយាល័យរដ្ឋបាល។ អង្គការសហប្រជាជាតិត្រូវធ្វើការទូទាត់ទៅឱ្យរាជរដ្ឋាភិបាលកម្ពុជាតាមវិក្កយបត្រទាំងនោះ បន្ទាប់ពីវិក្កយបត្រទាំងនោះត្រូវបានបញ្ជាក់ និងតាមចំនួនដែលបានទទួលយក ដោយអនុប្រធានការិយាល័យរដ្ឋបាល ឬតំណាងដែលត្រូវបានចាត់តាំងរបស់គាត់។

(ឃ) ទាក់ទងនឹងតម្លៃសម្រាប់ការប្រើប្រាស់បណ្ដាញទូរគមនាគមន៍តាមទូរសព្ទក្នុងតំបន់ គេយល់ឃើញថាអ្នកផ្ដល់សេវាកម្មពាណិជ្ជកម្មក្នុងស្រុកនឹងដាក់វិក្កយបត្រផ្ទាល់ទៅកាន់អនុប្រធានការិយាល័យរដ្ឋបាល។ អង្គការសហប្រជាជាតិនឹងធ្វើការទូទាត់ផ្ទាល់ទៅឱ្យអ្នកផ្ដល់សេវាកម្មពាណិជ្ជកម្មក្នុងស្រុក អនុលោមតាមលក្ខខណ្ឌកិច្ចសន្យាសេវាកម្មជាធរមាន។

## មាត្រា ៥
## ពន្ធ

១. អង្គការសហប្រជាជាតិត្រូវបានលើកលែងពីការយកពន្ធណាមួយ និងទាំងអស់ និងតម្លៃផ្សេងទៀតដែលមានលក្ខណៈសាធារណៈ ដែលត្រូវបានវាយតម្លៃ ឬអាចត្រូវបានវាយតម្លៃចំពោះអាគារ ឬទាក់ទងទៅនឹងអាគារ។

២. អង្គការសហប្រជាជាតិត្រូវបានលើកលែងពីការយកពន្ធណាមួយ និងទាំងអស់ ដោយផ្ទាល់ និងដោយប្រយោល រួមទាំងលើតម្លៃបន្ថែម ដែលអាចនឹងត្រូវបង់លើ ឬបង់ជាផ្នែកនៃថ្លៃ និងតម្លៃ ដែលបានបញ្ជាក់នៅក្នុងមាត្រា ៤ កថាខណ្ឌ ២ នៃកិច្ចព្រមព្រៀងបន្ថែមនេះ។

## មាត្រា ៦
## ជំនួយសង្គ្រោះបឋម និងសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ

១. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធ្វើឱ្យប្រាកដថាមានគ្រឿងបរិក្ខារវេជ្ជសាស្ត្រគ្រប់គ្រាន់នៅក្នុងអាគារ សម្រាប់ការសង្គ្រោះបឋមក្នុងករណីបន្ទាន់។

២. រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាឱ្យមានការចូលពិនិត្យ និងព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យកាល់ម៉ែតក្នុងរាជធានីភ្នំពេញ នៅពេលណាដែលត្រូវការ នៅក្នុងករណីសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ដែលកើតឡើងនៅក្នុងអាគារ។ រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវធានាផងដែរថា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង មានការ

ដឹកជញ្ជូនចាំបាច់សម្រាប់គោលបំណងនេះ តាមការហៅទូរស័ព្ទ នៅថ្ងៃទាំងអស់ និងគ្រប់ពេលវេលា និងម៉ោង មិនថាជាថ្ងៃធ្វើការ ឬម៉ោងធ្វើការ ឬផ្សេងពីនេះនោះឡើយ។

## មាត្រា៧
## ការដឹកជញ្ជូន

១. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវផ្តល់ការដឹកជញ្ជូនគ្រប់គ្រាន់ នៅថ្ងៃធ្វើការធម្មតា និងម៉ោងធ្វើការធម្មតា រវាងកណ្តាលទីក្រុងភ្នំពេញ និងអាគារសម្រាប់បុគ្គលិកអន្តរជាតិ និងបុគ្គលិកកម្ពុជា ដែលជួលដោយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ កាលវិភាគសម្រាប់សេវាទាំងនេះ និងទីតាំង និងផ្លូវរត់ដែលបម្រើសេវាកម្មនេះ ត្រូវមានការព្រមព្រៀងដាច់ដោយឡែក រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

២. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធានាឱ្យមានការដឹកជញ្ជូនគ្រប់គ្រាន់ នៅម៉ោងធ្វើការធម្មតា នៅថ្ងៃដែលកិច្ចដំណើរការនីតិវិធីកំពុងធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ រវាងកណ្តាលទីក្រុងភ្នំពេញ និងអាគារសម្រាប់សាធារណៈជន និងតំណាងសារព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមានបំណងចូលរួមកិច្ចដំណើរការនីតិវិធីទាំងអស់នោះ។ កាលវិភាគសម្រាប់សេវាកម្មទាំងអស់នេះ និងទីតាំង និងផ្លូវរត់ដែលបម្រើសេវាកម្មនេះ ត្រូវមានការព្រមព្រៀងដាច់ដោយឡែក រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

៣. រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវទាំងស្រុងចំពោះ និងត្រូវដោះស្រាយរាល់ការស្នើសុំ ការទាមទារ ការប្តឹងផ្តល់ និងការទទួលខុសត្រូវ ក្នុងលក្ខណៈនិងប្រភេទណាក៏ដោយ ដែលកើតចេញពី ឬទាក់ទងនឹងការដឹកជញ្ជូន ដែលខ្លួនអាចផ្តល់ឱ្យ អនុលោមតាមមាត្រានេះ ហើយត្រូវធានា និងការពារអង្គការសហប្រជាជាតិ មន្ត្រី ភ្នាក់ងារ ឈ្នួលរបស់ខ្លួន និងនិយោជិតពី និងប្រឆាំងនឹងការស្នើសុំ ការទាមទារ ការប្តឹងផ្តល់ និងការទទួលខុសត្រូវបែបនេះទាំងអស់នោះ។ រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវផ្តល់ និងរក្សាឱ្យមានការធានារ៉ាប់រងគ្រប់គ្រាន់ ដើម្បីរ៉ាប់រងលើការស្នើសុំ ការទាមទារ ការប្តឹងផ្តល់ និងការទទួលខុសត្រូវ។

៤. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវផ្តល់ និងរក្សាឱ្យមានទីធ្លាខាងក្រៅ និងជាប់ទៅនឹងអាគារផ្ទាល់ សម្រាប់ការចតយានជំនិះរបស់បុគ្គលិកកម្ពុជា និងអន្តរជាតិ ដែលជួលដោយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងយានជំនិះរបស់តំណាងរដ្ឋសមាជិកអង្គការសហប្រជាជាតិ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសមាជិកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសាធារណជន ដែលចូលរួមសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ទីតាំងមួយ ឬច្រើន ដែលផ្តល់និងរក្សាទុកចំណតបែបនេះ និងចំនួនយានជំនិះដែលទីតាំងចំណតទាំងនោះត្រូវដាក់ ត្រូវស្ថិតក្រោមការព្រមព្រៀងដាច់ដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

## មាត្រា ៨
## កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ ទាក់ទងនឹងអាគារ

អង្គការសហប្រជាជាតិធានាថា អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកអន្តរជាតិ ដែលខ្លួនបានជ្រើសរើស ត្រូវអនុវត្តការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន ចំពោះអាគារ និងគ្រឿងសង្ហារឹមរបស់អាគារ របស់របរដែលនៅជាប់នឹងអាគារ និងសម្ភារៈទាំងអស់ក្នុងអាគារ។

## មាត្រា ៩
## ការធានា និងការធានារ៉ាប់រង

១. ដោយមិនប៉ះពាល់ដល់ការធានាណាផ្សេងទៀតដែលខ្លួនបានផ្តល់ជូន នៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែម រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធានា លើកលែងការទទួលខុសត្រូវ

និងការពារ អង្គការសហប្រជាជាតិ មន្ត្រី ភ្នាក់ងារ ឈ្នួលរបស់ខ្លួន និងនិយោជិតពី និងប្រឆាំងនឹង ការស្នើសុំ ការទាមទារ ការប្តឹងផ្តល់ និងការទទួលខុសត្រូវគ្រប់ប្រភេទដែលកើតចេញពី ឬទាក់ទងនឹងការកាន់កាប់ ឬ ការប្រើប្រាស់អាគារដោយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ដោយអនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកអន្តរជាតិដែលជ្រើសរើសដោយអនុប្រធានការិយាល័យរដ្ឋបាល។

២. យោងតាមកថាខណ្ឌ ៣ ខាងក្រោម រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវចំពោះការបំពេញតាមការទាមទារណាមួយគ្រប់ប្រភេទរបស់តតិយជន និងការទទួលខុសត្រូវចំពោះតតិយជនសម្រាប់ការរងរបួសផ្ទាល់ខ្លួន ជំងឺ មរណភាព ឬការខូចខាតទ្រព្យសម្បត្តិ ដែលកើតឡើងនៅក្នុងអាគារ និងត្រូវធានា និងការពារអង្គការសហប្រជាជាតិ មន្ត្រី ភ្នាក់ងារ ឈ្នួល និងនិយោជិតរបស់អង្គការសហប្រជាជាតិ។

៣. អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវចំពោះ ការដោះស្រាយការទាមទារណាមួយក្នុងកំហុសស៊ីវិល ឬបទល្មើសដោយតតិយជនសម្រាប់ការរងរបួស ជំងឺ មរណភាព ឬការខូចខាតទ្រព្យសម្បត្តិដែលកើតចេញពីអំពើធ្វេសប្រហែសសកម្ម ឬអកម្ម របស់អង្គការសហប្រជាជាតិ ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល ឬបុគ្គលិកអន្តរជាតិ ដែលគាត់បានជ្រើសរើស និង សម្រាប់គោលបំណងនេះ ត្រូវរក្សាការធានារ៉ាប់រងបែបនោះ ដូចដែលចាំបាច់ ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនយោងតាមកថាខណ្ឌនេះ។

៤. មុនពេលធ្វើការទាមទារណាមួយប្រឆាំងនឹងអង្គការសហប្រជាជាតិ ទាក់ទងនឹងការខូចខាតចំពោះអាគារ គ្រឿងសង្ហារឹមរបស់អាគារ របស់របរដែលនៅជាប់នឹងអាគារ និងសម្ភារៈទាំងអស់ក្នុងអាគារ ឬទាក់ទងនឹងការរងរបួសលើបុគ្គល ឬទ្រព្យសម្បត្តិ ដែលបង្កឡើងដោយអង្គការសហប្រជាជាតិ ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល ឬបុគ្គលិកអន្តរជាតិ ដែលគាត់បានជ្រើសរើស រាជរដ្ឋាភិបាលកម្ពុជា ជាដំបូង ត្រូវពិនិត្យមើលការធានារ៉ាប់រងណាមួយតាមការចង់បានរបស់ខ្លួន។

៥. គេយល់ឃើញថាអង្គការសហប្រជាជាតិនឹងទទួលបាន និងរក្សាទុកនូវការធានារ៉ាប់រងគ្រប់គ្រាន់សម្រាប់បរិក្ខារ ឧបករណ៍ ការផ្តល់ ការផ្គត់ផ្គង់ សម្ភារៈ និងទំនិញផ្សេងៗទៀត ដែលអាចដំឡើង ប្រតិបត្តិការ ឬរក្សាទុកដោយអង្គការសហប្រជាជាតិនៅក្នុងអាគារ ឬថា ម្យ៉ាងវិញទៀត អាចត្រូវបានផ្តល់ដោយអង្គការសហប្រជាជាតិសម្រាប់គោលបំណងគាំទ្រប្រតិបត្តិការរបស់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

## <u>មាត្រា ១០</u>
## <u>ការដោះស្រាយជម្លោះ</u>

ជម្លោះណាមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចា ឬទម្រង់នៃការដោះស្រាយដែលបានព្រមព្រៀង ត្រូវបញ្ជូនតាមសំណើរបស់ភាគីណាមួយស្នើសុំសេចក្តីសម្រេចស្ថាពរទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះដែលមានសមាសភាពមជ្ឈត្តករបីរូប ក្នុងនោះមជ្ឈត្តករមួយរូបត្រូវតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ម្នាក់ទៀតត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈត្តករទីបី ដែលត្រូវធ្វើជាប្រធាន ត្រូវជ្រើសរើសដោយមជ្ឈត្តករពីររូបដំបូង។ ប្រសិនបើភាគីណាមួយខកខានក្នុងការតែងតាំងមជ្ឈត្តករក្នុងរយៈពេល ៦០ ថ្ងៃ នៃការតែងតាំងដោយភាគីមួយផ្សេងទៀត ឬប្រសិនបើមជ្ឈត្តករទាំងពីររូបនេះមិនឯកភាពគ្នាក្នុងការជ្រើសរើសមជ្ឈត្តករទីបីក្នុងរយៈពេល ៦០ ថ្ងៃ នៃការតែងតាំងរបស់ខ្លួន ប្រធានតុលាការយុត្តិធម៌អន្តរជាតិ អាចធ្វើការតែងតាំងណាមួយដែលចាំបាច់ តាមការស្នើសុំរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ។ ទោះជាយ៉ាងណា ជម្លោះណាមួយបែបនេះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាចោទដែលបញ្ញត្តដោយអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ត្រូវដោះស្រាយអនុលោមតាមជំពូក ៣០ នៃអនុសញ្ញានោះ។

## <u>មាត្រា ១១</u>

**<u>បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ</u>**

មិនមានចំណុចណានៅក្នុង ឬទាក់ទងទៅនឹងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវចាត់ទុកថាជាការបោះបង់ ដោយផ្ទាល់ ឬដោយតុណ្ហីភាព នៃបុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយរបស់អង្គការសហប្រជាជាតិ ឬនៃបុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយដែលមានចែងនៅក្នុង**កិច្ចព្រមព្រៀង**ឡើយ។

**<u>មាត្រា ១២</u>**
**<u>ការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការ</u>**

ក្នុងករណីដែលថា និងប្រសិនបើ អង្គការសហប្រជាជាតិអាចអនុវត្តសិទ្ធិរបស់ខ្លួនយោងតាមមាត្រា ២៨ នៃ**កិច្ចព្រមព្រៀង** ដើម្បីឈប់ផ្តល់ជំនួយ អនុលោមតាម**កិច្ចព្រមព្រៀង** នោះកាតព្វកិច្ចនានារបស់អង្គការសហប្រជាជាតិយោងតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវឈប់អនុវត្ត។

**<u>មាត្រា ១៣</u>**
**<u>ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀង</u>**

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវបកស្រាយ និងអនុវត្តក្នុងលក្ខខណៈមួយដែលស្របជាមួយនឹងពាក្យពេចន៍នៃ**កិច្ចព្រមព្រៀង**។

**<u>មាត្រា ១៤</u>**
**<u>ការចូលជាធរមាន</u>**

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវចូលជាធរមានភ្លាមបន្ទាប់ពីចុះហត្ថលេខា។

**<u>មាត្រា ១៥</u>**
**<u>ការបញ្ចប់</u>**

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវនៅជាធរមានដរាបណា**កិច្ចព្រមព្រៀង**នៅជាធរមាន។ កិច្ចព្រមព្រៀងបំពេញបន្ថែមត្រូវបញ្ចប់នៅពេលដែល**កិច្ចព្រមព្រៀង**បញ្ចប់។

ធ្វើនៅភ្នំពេញនៅ __________ ឆ្នាំ២០០៦ ជាពីរច្បាប់ជាភាសាអង់គ្លេស។

| **ភាគីរាជរដ្ឋាភិបាលកម្ពុជា** | **ភាគីអង្គការសហប្រជាជាតិ** |
|---|---|
| *ហត្ថលេខា* | *ហត្ថលេខា* |
| **ស៊ាន វិសុទ្ធ** | Michelle Lee |
| **ប្រធានការិយាល័យរដ្ឋបាល** | **អនុប្រធានការិយាល័យរដ្ឋបាល** |
| **អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** | **អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** |